**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកាត់ឆ្វៀលដីទំហំ ៥២,២៨ ហិកតា ស្ថិតនៅក្រុងកោះរ៉ុង**

**ចេញពីដីឯកជនរបស់រដ្ឋកំណត់ដោយអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០០៨**

**សម្រាប់ប្រគល់ជូនរដ្ឋបាលខេត្តព្រះសីហនុ ធ្វើជាតំបន់រដ្ឋបាលប្រមូលផ្តុំក្រុងកោះរ៉ុង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៨ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ ស្តីពីការធ្វើអនុបយោគទីតាំងកោះរ៉ុង កោះរ៉ុងសន្លឹម កោះឫស្សី កោះពោធិ៍ និងកោះកូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



**សម្រេច**

**មាត្រា ១ :** កាត់ឆ្វៀលដីសរុបទំហំ ៥២,២៨ហិកតា ចេញពីដីឯកជនរបស់រដ្ឋ កំណត់ដោយអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០៨ ក្នុងនោះទំហំ ៣៧,៩៥ហិកតា សម្រាប់សាងសង់ជាអគាររដ្ឋបាលប្រមូលផ្តុំក្រុងកោះរ៉ុង រួមមាន÷ សាលាក្រុងកោះរ៉ុង រដ្ឋបាលសង្កាត់កោះរ៉ុង ប៉ុស្តិ៍នគរបាលសង្កាត់កោះរ៉ុងសន្លឹម មណ្ឌលសុខភាព មណ្ឌលព័ត៌មានទេសចរណ៍ សារមន្ទីរក្រុងកោះរ៉ុង សាលារៀន ផ្សារ សួនច្បារ និងសម្រាប់រៀបចំជាតំបន់សហគមន៍ និងទំហំ ១៤,៣២ហិកតា សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយអនុវត្តតាមប្លង់គោលប្រើប្រាស់ដីកោះរ៉ុង របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានផែនទីបង្ហាញទីតាំងដី និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ។

**មាត្រា ២ :** ត្រូវបានកែសម្រួលទំហំដីនៅក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.ន ០០៨៣២៦ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៩ ហើយចុះបញ្ជីបំបែកក្បាលដី និងចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែងថ្មី ជូនក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប ខូអិលធីឌី សម្រាប់បន្តធ្វើការវិនិយោគ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទី និងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៥៦ អនក្រ.បក...ចុះថ្ងៃទី...២៣......ខែ...មេសា....ឆ្នាំ២០២០




**សញ្ញាសម្គាល់**

- ចំណុចនិយាមការព្រំដីទំហំ ៥២២ ៨៥១ ម²
- ដីទំហំ ៥២២ ៨៥១ ម² ស្នើសុំកាត់ចេញពីដីរបស់រដ្ឋខេត្តព្រះសីហនុ ដែលក្នុងនោះ :
- ដីទំហំ ៣៧៩ ៥៧៩ ម² សម្រាប់សាងសង់អគាររដ្ឋបាលប្រមូលផ្តុំក្រុងកោះរ៉ុង
  ដីទំហំ ១៤៣ ២៧២ ម² សម្រាប់សាងសង់ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ
- ឧទ្យានជាតិសមុទ្រកោះរ៉ុង
- ផ្លូវ

តារាងនិយាមការព្រំដីទំហំ ៥២,២៨ ហិតា

Projection , UTM, Zone 48N

Datum, WGS,1984

| ID | Easting | Northing | ID | Easting | Northing |
|---|---|---|---|---|---|
| 1 | 311181.951 | 1180855.721 | 42 | 311580.308 | 1181869.398 |
| 2 | 311190.761 | 1180879.801 | 43 | 311534.614 | 1181897.588 |
| 3 | 311193.120 | 1180886.247 | 44 | 311463.319 | 1181948.978 |
| 4 | 311193.932 | 1180894.577 | 45 | 311386.141 | 1182001.478 |
| 5 | 311194.866 | 1180904.146 | 46 | 311382.740 | 1182005.584 |
| 6 | 311196.535 | 1180939.762 | 47 | 311346.895 | 1181961.966 |
| 7 | 311197.430 | 1180943.468 | 48 | 311295.301 | 1181903.229 |
| 8 | 311202.422 | 1180964.150 | 49 | 311258.788 | 1181874.654 |
| 9 | 311203.742 | 1180969.620 | 50 | 311243.066 | 1181856.920 |
| 10 | 311209.079 | 1180991.731 | 51 | 311229.687 | 1181841.830 |
| 11 | 311217.806 | 1181006.550 | 52 | 311216.910 | 1181826.331 |
| 12 | 311228.694 | 1181025.039 | 53 | 311192.113 | 1181794.882 |
| 13 | 311239.400 | 1181043.220 | 54 | 311172.666 | 1181765.116 |
| 14 | 311270.714 | 1181089.650 | 55 | 311134.301 | 1181694.869 |
| 15 | 311299.646 | 1181130.081 | 56 | 311083.898 | 1181617.081 |
| 16 | 311313.287 | 1181149.142 | 57 | 311053.736 | 1181570.647 |
| 17 | 311359.287 | 1181196.445 | 58 | 311033.495 | 1181537.309 |
| 18 | 311371.305 | 1181208.803 | 59 | 311031.023 | 1181530.739 |
| 19 | 311417.086 | 1181249.679 | 60 | 311024.367 | 1181503.972 |
| 20 | 311470.771 | 1181291.061 | 61 | 311018.017 | 1181473.412 |
| 21 | 311508.546 | 1181308.768 | 62 | 311011.270 | 1181433.724 |
| 22 | 311517.362 | 1181311.616 | 63 | 311008.889 | 1181403.165 |
| 23 | 311548.617 | 1181321.714 | 64 | 311008.492 | 1181365.462 |
| 24 | 311571.228 | 1181320.921 | 65 | 311010.476 | 1181330.537 |
| 25 | 311583.701 | 1181320.483 | 66 | 311019.604 | 1181279.340 |
| 26 | 311596.576 | 1181319.477 | 67 | 311028.336 | 1181235.684 |
| 27 | 311645.976 | 1181326.184 | 68 | 311039.845 | 1181180.915 |
| 28 | 311658.794 | 1181329.940 | 69 | 311056.117 | 1181108.683 |
| 29 | 311665.144 | 1181331.332 | 70 | 311052.545 | 1181063.439 |
| 30 | 311715.993 | 1181341.603 | 71 | 311046.592 | 1181028.911 |
| 31 | 311740.308 | 1181360.662 | 72 | 311029.526 | 1180964.221 |
| 32 | 311770.509 | 1181382.138 | 73 | 311013.254 | 1180924.136 |
| 33 | 311797.844 | 1181419.844 | 74 | 311002.460 | 1180899.748 |
| 34 | 311825.791 | 1181472.664 | 75 | 311007.510 | 1180895.851 |
| 35 | 311845.994 | 1181515.809 | 76 | 311026.472 | 1180890.385 |
| 36 | 311876.895 | 1181565.298 | 77 | 311062.939 | 1180886.111 |
| 37 | 311881.697 | 1181663.482 | 78 | 311087.012 | 1180873.776 |
| 38 | 311804.711 | 1181716.465 | 79 | 311106.218 | 1180869.219 |
| 39 | 311747.380 | 1181754.563 | 80 | 311134.672 | 1180862.469 |
| 40 | 311695.622 | 1181787.767 | 81 | 311156.383 | 1180857.319 |
| 41 | 311646.299 | 1181821.426 | 82 | 311173.072 | 1180856.276 |